គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ៥៦ ចេញផ្សាយថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២
No. 56 Released on October 14, 2022

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# លក្ខខណ្ឌតម្រូវអាជ្ញាបណ្ណធ្វើជាបរធនបាលរូបវន្តបុគ្គលឯករាជ្យ

## Requirements for Licensing for Independent Physical Trustee



https://www.vectorstock.com/royalty-free-vector/people-business-man-give-document-vector-28207814

យោងតាមច្បាប់ស្តីពី “បរធនបាលកិច្ច” (២០១៩), បទប្បញ្ញត្តិពាក់ព័ន្ធ និងប្រកាសលេខ ០០៣/អ.ស.ហ./ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពី “វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច” ដើម្បីទទួលបានអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាបរធនបាលរូបវន្តបុគ្គលឯករាជ្យ បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម÷

**១.** លក្ខខណ្ឌដូចមានចែងក្នុងចំណុច៨, ៩, ១១, ១២ និង១៣ នៃប្រការ១៦ និងចំណុច១, ២, ៥, និង៦ នៃប្រការ២៦ នៃប្រកាសនេះ។

**២.** បំពេញលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម សម្រាប់ធ្វើជាបរធនបាលរូបវន្តបុគ្គលឯករាជ្យ÷

**ក.** ជាមេធាវីដែលទទួលបានវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសមាការី (Associate) ឬជាសមាជិក (Member) នៃការិយាល័យ ឬក្រុមហ៊ុនមេធាវីនៅព្រះរាជាណាចក្រកម្ពុជា។

**ខ.** ជាសារការី ដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ឬលិខិតរបស់ក្រសួងយុត្តិធម៌ និងជាសមាការី (Associate) ឬសមាជិកសារការី (Member) នៃមន្ទីរសារការីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**គ.** ជាអភិបាលបណ្តោះអាសន្ន ដែលត្រូវបានចុះបញ្ជីទទួលស្គាល់ ដោយស្ថាប័នមានសមត្ថកិច្ចនៅក្នុងព្រះរាជាណាចកម្ពុជា។

**ឃ.** ជាអភិបាលឯករាជ្យនៃក្រុមហ៊ុន ដែលមិនពាក់ព័ន្ធនឹងទំនាក់ទំនងផលប្រយោជន៍ជាមួយក្រុមហ៊ុនបរធនបាល ឬបរធន-បាលទាយក ឬអត្ថគាហកៈនៃបរធនបាលកិច្ច។

**ង.** ធ្លាប់ជាប្រធានក្រុមប្រឹក្សា ឬអភិបាល ឬនាយកប្រតិបត្តិ ឬប្រធានផ្នែកហិរញ្ញវត្ថុ ឬប្រធានប្រតិបត្តិការ ឬប្រធានសាខានៃក្រុមហ៊ុនណាមួយ។

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

**ច.** ធ្លាប់ទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាតធ្វើជាបរធនបាលបុគ្គល រយៈពេលយ៉ាងតិច ៣ (បី) ឆ្នាំ ពីយុត្តាធិការដែលទទួលស្គាល់ដោយ **ន.ប.ធ.**។

**ឆ.** ជាគណនេយ្យករជំនាញនៃក្រុមហ៊ុនសវនកម្ម។

**ជ.** ជាអ្នកវិភាគហិរញ្ញវត្ថុជំនាញ (Certified Financial Analyst) ឬគណនេយ្យករជំនាញ (Certified Public Accountant) ដែលជាសមាជិកសកម្មរបស់ **វ.គ.ស.ក.**។

**ឈ.** បុគ្គលធ្លាប់ទទួលបានអាជ្ញាបណ្ណធ្វើជាបរធនបាលរូបវន្តបុគ្គលដោយ **ន.ប.ធ.**។

**ញ.** បុគ្គលធ្លាប់ទទួលបានអាជ្ញាបណ្ណធ្វើជាភ្នាក់ងារគ្រប់គ្រងមូលនិធិពីនិយ័តករមូលបត្រកម្ពុជា។

**៣.** បរធនបាលរូបវន្តបុគ្គលឯករាជ្យត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម÷

**ក.** ដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល ក្នុងគណនីរបស់ **ន.ប.ធ.** នៅធនាគារជាតិនៃកម្ពុជា។

**ខ.** រក្សាទុកទ្រព្យសម្បត្តិបរធនបាលកិច្ច ឬតម្កល់មូលនិធិ សម្រាប់បរធនបាលកិច្ចនីមួយៗ នៅបុគ្គលថែរក្សាសុវត្ថិភាពដែលទទួលបានការអនុញ្ញាត និង/ ឬការចុះបញ្ជីពីអគ្គនាយកនៃ **ន.ប.ធ.** ឬក្រុមហ៊ុនបរធនបាល ដែលទទួលបានអាជ្ញាបណ្ណ និង/ ឬការអនុញ្ញាតពីអគ្គនាយកនៃ **ន.ប.ធ.** ឬ បុគ្គលផ្សេងទៀត ដែលបានការអនុញ្ញាតពីអគ្គនាយកនៃ **ន.ប.ធ.**។ បែបបទ និងយន្តការរក្សាទុកទ្រព្យសម្បត្តិបរធនបាលកិច្ច ឬការតម្កល់មូលនិធិនេះ ត្រូវស្ថិតនៅក្រោមការកំណត់របស់ **ន.ប.ធ.**។

According to the Law on Trust (2019), relevant provisions and Prakas No. 003 dated January 26, 2022, on "Rules on the Management, Organization, and the Functioning of Trust", in order to obtain a license or renew its license as an independent physical trustee, an applicant must meet the following conditions:

1. The conditions as stated in points 8, 9, 11, 12 and 13 of Article 16 and points 1, 2, 5, and 6 of Article 26 of the Prakas on the rules governing the organization and functioning of trustee.

2. Fulfill any of the following conditions for becoming an independent physical trustee:

A. Is a lawyer who has received a professional certificate from the Bar Association of the Kingdom of Cambodia and an Associate or a member of an office or law firm in the Kingdom of Cambodia.

B. A notary who has been appointed by the Royal Government or appointed by a legal document or letter from the Ministry of Justice and is an Associate or a notary member of the Notary Department in Cambodia.

C. An interim governor who is registered and recognized by the competent authority in Cambodia.

D. An independent director of a company that is not involved in a relationship of interests with the trust company or trustor or beneficiary of the trust.

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

E. Formerly was Chairman of the Board or director or Chief Executive Officer or Chief Financial Officer or Chief Operating Officer or Branch Manager of any company.

F. Have obtained a license or permit for personal trust for at least three (3) years from the jurisdiction recognized by trust regulator.

G. A professional accountant of an audit firm.

H. A Certified Financial Analyst or a Certified Public Accountant who is an active member of the Institute of CPAs and Auditors (KICPAA).

I. Individual has been licensed as a physical trustee by the trust regulator.

J. Individual who has been licensed as a fund management agent by the Securities and Exchange Commission of Cambodia.

3. The independent physical trustee must meet the following conditions:

A. Deposit 80,000,000 (eighty million) Riels for business guarantee in the account of Trust at the National Bank of Cambodia.

B. Retain the trust asset or provide funds for each trust at the custodian who has received permission and / or registration from the Director General of Trust Regulator or trust company licensed and / or authorized by the Director General of trust regulator or any other individuals authorized by the Director General of trust regulator. The procedures and mechanisms for the storage of assets or deposit of this fund shall be subject to the determination of trust regulator.

**អត្ថបទ÷ កញ្ញា ភាន់ វីរ៉ាលីន | Article: PHORN Viralynn**

**ឯកសារយោង | References:**

- ច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩)
- អនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ (២០១៣)
- ប្រកាសស្តីពីវិធានគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច (២០២២)

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.